លេខ ១៦៨ ថ្ងៃច័ន្ទ ទី១២ ខែកញ្ញា ឆ្នាំ២០០៥

ពត៌មានក្នុងប្រទេស

# សម្តេច ហ៊ុន សែន ដឹកនាំប្រតិភូក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ចូលក្រាបបង្គំគាល់ព្រះមហាក្សត្រ

*លោក ចង លឹមអ៊ី AKP ភ្នំពេញ*

កាលពីល្ងាចថ្ងៃទី០៩ កញ្ញា ឆ្នាំ២០០៥ ថ្មីៗកន្លងទៅនេះ នៅព្រះបរមរាជវាំង ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី បានសព្វព្រះរាជហឫទ័យប្រោសព្រះរាជានុញ្ញាតឱ្យសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំគណៈប្រតិភូជាតិក្រសួងវប្បធម៌ និងវិចិត្រសិល្បៈចូលក្រាបបង្គំគាល់ ដើម្បីទូលថ្វាយពីសកម្មភាពការងារ ដែលក្រសួងបានប្រឹងប្រែងអនុវត្ត នាពេលកន្លងមក ។

មានប្រសាសន៍នាឱកាសដ៏ថ្លៃថ្លានោះ សម្តេចនាយករដ្ឋមន្ត្រីបានបង្គំទូលថ្វាយនូវអំណរព្រះគុណដ៏ជ្រាលជ្រៅបំផុត ដែលព្រះករុណាបានសព្វព្រះរាជហឫទ័យប្រោសព្រះរាជានុញ្ញាតឱ្យសម្តេចដឹកនាំថ្នាក់ដឹកនាំក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ចូលក្រាបបង្គំគាល់ថ្វាយពីរបាយការណ៍ដូចបណ្តាក្រសួងដទៃទៀត នាពេលកន្លងមក ។

អ្នកអម្ចាស់ ស៊ីសុវត្ថិ បណ្ណារ៉ា សេរីវុធ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានទូលថ្វាយអំពីសកម្មភាព និងលទ្ធផលក្នុងផ្នែកនានា ពិសេសការងារអភិរក្សវិស័យវប្បធម៌ ការគ្រប់គ្រងត្រួតពិនិត្យសិក្សាការងារអភិរក្សបេតិកភ័ណ្ឌវប្បធម៌ជាតិ ដោយប្រើប្រាស់វិធានការអប់រំផ្សព្វផ្សាយវិធានការច្បាប់ និងវិធានការចុះអនុវត្តផ្ទាល់ ដើម្បីធានាបាននូវការគង់វង្សនៃសម្បត្តិវប្បធម៌ជាតិខ្មែរ ដែលមានតំលៃថ្លៃថ្លាមិនអាចកាត់ថ្លៃបាន ។ អ្នកអម្ចាស់ក៏បានលើកឡើងផងដែរពីការរីកចំរើនលើវិស័យសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌កំពុងមានដំណើរការយ៉ាងល្អប្រសើរឡើងវិញ តាមរយៈការផលិតខ្សែភាពយន្តវីដេអូរឿងខ្មែរ ការប្រលងស្នាដៃម្ហូបអាហារខ្មែរ ម៉ូតសំលៀកបំពាក់បុរាណ សម័យ និងការបង្កើតខ្លែងខ្មែរ ការបង្ហាញក្បាច់គុណបុរាណខ្មែរ និងអក្សរសាស្ត្រខ្មែរជាដើម ។

សម្តេចនាយករដ្ឋមន្ត្រី បានទូលថ្វាយបន្ថែមអំពីការខិតខំជាដរាបរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការគិតគូរខ្ពស់អំពីវប្បធម៌ សិល្បៈ ប្រពៃណី ទំនៀមទំលាប់របស់ប្រជាជាតិខ្មែរ ដែលមានភាពល្អផូរផង់តាំងពីបុរាណកាលមក ។ សម្តេចបានទូលថ្វាយផងដែរ អំពីការយកចិត្តទុកដាក់ចំពោះក្រុមសិល្បៈករ សិល្បៈការិនីលើការសម្តែងអាកប្បកិរិយាក្បាច់រាំ សំលៀកបំពាក់នៅពេលប្រគំតន្ត្រីតាមប៉ុស្តិ៍ទូរទស្សន៍ និងខ្សែភាព

យន្តក្នុងការថែរក្សាតំលៃសិល្បៈវប្បធម៌ក្នុងសង្គមជាតិយើង ។

ព្រះករុណា បានសព្វព្រះរាជហឫទ័យ មានព្រះរាជបន្ទូលកោតសរសើរ ថ្លែងអំណរគុណចំពោះសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងគណៈប្រតិភូដែលបានក្រាបបង្គំគាល់រាយការណ៍ពីសកម្មភាពការងាររបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលបានបង្ហាញឱ្យឃើញនូវការយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់ឧត្តុង្គឧត្តមពីសំណាក់សម្តេចថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់លើវិស័យវប្បធម៌ជាតិខ្មែរយើង ។ ព្រះករុណាមានព្រះរាជឱង្ការឱ្យសម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី មេត្តាបន្តការងារជួយថែរក្សាការពារសម្បត្តិវប្បធម៌ និងវិចិត្រសិល្បៈឱ្យបានគង់វង្សរៀងរហូត ព្រោះសិល្បៈវប្បធម៌ជាព្រលឹងរបស់ប្រជាជាតិយើង ដែលជាកេរ្តិ៍មរតកដ៏ថ្លៃថ្លាបំផុត ពុំអាចកាត់ថ្លៃបានរបស់បុព្វបុរសជាតិខ្មែរយើង ។/

## សម្តេច ហ៊ុន សែន អញ្ជើញទៅចូលរួមមហាសន្និបាតអង្គការសហប្រជាជាតិ

*លោក ជ័យ ភូមិពល AKP ភ្នំពេញ*

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់រាជរដ្ឋាភិបាលកម្ពុជា ឆ្ពោះទៅកាន់បូរីញូវយ៉កកាលពីថ្ងៃទី១០ កញ្ញា ដើម្បីចូលរួមក្នុងកិច្ចប្រជុំចំនួនពីរដែលមានសារៈសំខាន់នោះ ។

យាង និងអញ្ជើញជូនដំណើរគណៈប្រតិភូជាន់ខ្ពស់នៅឯព្រលានយន្តហោះអន្តរជាតិភ្នំពេញ មានជាអាទិ៍ ឯកឧត្តម ជាឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ ជារដ្ឋមន្ត្រី រដ្ឋលេខាធិការព្រមទាំងអស់លោក ជាឯកអគ្គរដ្ឋទូត ឯកអគ្គរាជទូត នៃបណ្តាប្រទេសជាមិត្តប្រចាំនៅកម្ពុជាផងដែរ ។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឱ្យដឹងថា: សម្តេចនាយករដ្ឋមន្ត្រីនឹងចូលរួមកិច្ចប្រជុំលើកទី២ អាស៊ាន អង្គការសហប្រជាជាតិ និងកិច្ចប្រជុំពេញអង្គថ្នាក់ខ្ពស់នៃមហាសន្និបាតអង្គការសហប្រជាជាតិលើកទី៦០ ដែលប្រព្រឹត្តទៅពីថ្ងៃទី១៣ ដល់ថ្ងៃទី១៦ ខែកញ្ញា ហើយលោកនឹងថ្លែងសុន្ទរកថាមួយនៅថ្ងៃទី១៥ វេលាម៉ោង ១០ និង ៤៥នាទី ម៉ោងនៅទីក្រុងភ្នំពេញ ។

សេចក្តីប្រកាសព័ត៌មាននិយាយថា សម្តេចនាយករដ្ឋមន្ត្រីនឹងអញ្ជើញទៅធ្វើទស្សនកិច្ចការងារនៅសាធារណរដ្ឋបារាំងចំនួន ២ថ្ងៃ (១៩-២០ ០៩ ២០០៥) ដែលនៅទីនោះលោកនឹងជួបសំដែងការគួរសមជាមួយលោកប្រធានាធិបតី ហ្សាក់ស៊ីរ៉ាក់ ជួបជាមួយរដ្ឋមន្ត្រីរបស់បារាំង ព្រមទាំងជួបជាមួយអ្នកវិនិយោគទុនបារាំងផងដែរ ។

សម្តេចនាយករដ្ឋមន្ត្រីគ្រោងនឹងវិលត្រឡប់មកកម្ពុជាវិញនៅថ្ងៃទី២២ ខែកញ្ញា បន្ទាប់ពីធ្វើទស្សនកិច្ចនៅបរទេសអស់រយៈពេល ១២ថ្ងៃ នោះ ។/

# កិច្ចប្រជុំគណៈរដ្ឋមន្ត្រី ថ្ងៃទី ៩ កញ្ញា ២០០៥

*លោក ពេជ្រ ណារិទ្ធ AKP ភ្នំពេញ*

សេចក្តីព្រាងច្បាប់ ស្តីពីជីវសុវត្ថិភាពត្រូវបានសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃ សុក្រ ចុងសប្តាហ៍មុន លើកយកមកពិនិត្យ និងពិភាក្សា ។

សេចក្តីប្រកាសពត៌មានដែលចេញផ្សាយដោយការិយាល័យអ្នកនាំពាក្យរាជរដ្ឋាភិបាល បានអោយដឹងថា : អង្គប្រជុំកាលពីថ្ងៃទី ៩ កញ្ញា ២០០៥ ក្រោមអធិបតីភាព សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន សំរេចឯកភាពលើសេចក្តីព្រាងច្បាប់នេះ ដែលត្រូវបានរៀបចំឡើងដោយក្រសួងបរិស្ថានក្រោមជំនួយបច្ចេកទេសពីមូលនិធិបរិស្ថានពិភពលោក និងកម្មវិធីបរិស្ថានសហប្រជាជាតិ ដោយផ្អែកតាមស្មារតីនៃពិធីសារកាតាហេង្សណា ស្តីពីជីវសុវត្ថិភាព និងសំរាប់ជាតំរូវការចាំបាច់របស់ព្រះរាជាណាចក្រកម្ពុជា ដើម្បីទប់ស្កាត់ហានិភ័យ ដែលបណ្តាលមកពីការប្រើប្រាស់សារពាង្គកាយកែច្នៃរស់ (Living Modified Organism ¨LMOs¨ ) ។ សេចក្តីព្រាងនេះ មានគោលបំណង :

-អនុវត្តនូវគោលការណ៍ប្រុងប្រយ័ត្នស្តីពីជីវសុវត្ថិភាព

-ទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានទៅលើការអភិរក្សជីវៈចំរុះ និងធនធានធម្មជាតិ

-ធានាប្រសិទ្ធិភាពនៃការអភិរក្ស និងការប្រើប្រាស់ជីវៈចំរុះដោយនិរន្តរភាព ព្រមទាំងយកចិត្តទុកដាក់ចំពោះហានិភ័យដល់សុខភាពមនុស្ស

-ធ្វើអោយមានតម្លាភាពក្នុងនីតិវិធីពិនិត្យ និងក្នុងការធ្វើសេចក្តីសំរេច ចំពោះសារពាង្គកាយកែច្នៃរស់ និងសកម្មភាពទាំងឡាយដែលទាក់ទងនឹងសារពាង្គកាយកែច្នៃរស់

-លើកកំពស់ការយល់ដឹងអំពីជីវបច្ចេកទេសទំនើប សំដៅទប់ស្កាត់ហានិភ័យពីការប្រើប្រាស់ និងការបញ្ចេញសារពាង្គកាយកែច្នៃរស់នៅក្នុងបរិស្ថាន និងសុខភាពមនុស្ស ។

សេចក្តីព្រាងច្បាប់ស្តីពីជីវសុវត្ថិភាព ចែកចេញជា ១១ជំពូក និង ៤៥មាត្រា ដែលគោលដៅនៃច្បាប់ គឺដើម្បីរួមវិភាគទានក្នុងការធានាកំរិតការពារឱ្យបានសមស្របនៅក្នុងការផ្ទេរការគ្រប់គ្រង និងការប្រើប្រាស់អោយមានសុវត្ថិភាពនៃសារពាង្គកាយកែច្នៃរស់ ដែលជាលទ្ធផលនៃជីវបច្ចេកវិទ្យាទំនើប អាចនាំមកនូវផលប៉ះពាល់អវិជ្ជមានដល់ការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនូវធនធានជីវចំរុះ ដោយគិតគូអំពីហានិភ័យដល់សុខភាពមនុស្ស និងជាពិសេសផ្តោតការចាប់អារម្មណ៍សំខាន់ទៅលើចលនាឆ្លងដែនផងដែរ ដែលរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ស្របតាមគោលនយោបាយចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ។

សេចក្តីប្រកាសពត៏មានខាងលើបានបង្ហាញអោយដឹងបន្ថែមទៀតថា អង្គប្រជុំគណៈរដ្ឋមន្ត្រីបានឯកភាពបញ្ជូន " កិច្ចព្រមព្រៀងសហប្រតិបត្តិការក្នុងតំបន់ ស្តីពីការប្រយុទ្ធប្រឆាំងអំពើប្លន់នាវា និងអំពើប្លន់ប្រដាប់អាវុធក្នុងដែនសមុទ្រអាស៊ី " ទៅស្ថាប័ននីតិប្បញ្ញត្តិ ដើម្បីសុំសច្ចាប័ន ។

-ទន្ទឹមនឹងនេះ អង្គប្រជុំគណៈរដ្ឋមន្ត្រីបានឯកភាពក្នុងស្មារតីមនុស្សធម៌ ផ្តល់ថវិកា ២០.០០០ ដុល្លាអាមេរិក (ពីម៉ឺនដុល្លារអាមេរិកគត់) ជួយដល់ជនរងគ្រោះដោយខ្យល់ព្យុះកាទ្រីណា ដែលបានបោកបក់ប៉ះទៅលើរដ្ឋមួយចំនួននៅសហរដ្ឋអាមេរិក ។/

## រដ្ឋសភានឹងបន្តសម័យប្រជុំលើកទី ៣ នីតិកាលទី ៣
## ថ្ងៃ អង្គារ ទី ១៣ កញ្ញា

*AKP ភ្នំពេញ*

តាមសេចក្តីជូនដំណឹង ចុះហត្ថលេខាថ្ងៃទី៨ កញ្ញា ដោយឯកឧត្តម ចាន់ វ៉េន អគ្គលេខាធិការស្តីទី មានខ្លឹមសារថា : អគ្គលេខាធិការដ្ឋានរដ្ឋសភា មានកិត្តិយសជម្រាបជូនសាធារណជនថា រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា នឹងបន្តសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៣ នៅថ្ងៃអង្គារ ទី១៣ ខែកញ្ញា ឆ្នាំ២០០៥ វេលាម៉ោង ៨,០០ព្រឹក នៅសាលប្រជុំរបស់រដ្ឋសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេច ហេង សំរិន ប្រធានរដ្ឋសភាស្តីទី ។

របៀបវារៈ នៃសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៣ នាថ្ងៃអង្គារ ទី១៣ ខែកញ្ញា ឆ្នាំ២០០៥នេះ មាន :

១-ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

២-ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់

អាស្រ័យហេតុនេះ សូមសាធារណជនជ្រាប ។/

## ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច មានភាពស្មុគ្រស្មាញលើការគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋ និងអាវុធជាតិផ្ទុះ

*លោក លឹម សាន្ត AKP កំពង់ស្ពឺ*

សព្វថ្ងៃនេះ ការគ្រប់គ្រងស្ថិតិប្រជារាស្ត្រ និងអាវុធជាតិផ្ទុះនៅក្នុងខេត្តកំពង់ស្ពឺ មានបញ្ហាស្មុគ្រស្មាញនៅឡើយ ពិសេសនៅឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ដែលអាជ្ញាធរខេត្តយល់ថា មានភូមិសាស្ត្រស្មុគ្រស្មាញជាងគេ ។

លោក រៀម ចន្ទម្នី អភិបាលរងខេត្តកំពង់ស្ពឺ និងជាប្រធានយុទ្ធនាការស្រង់ស្ថិតិ និងដកហូតអាវុធជាតិផ្ទុះបានឱ្យដឹងថា ការគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋ និងគ្រប់គ្រងអាវុធជាតិផ្ទុះ គឺមានបំណងពង្រឹងសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គមឱ្យមានស្ថិរភាព និងភាពសុខសាន្តជូនប្រជាពលរដ្ឋ ។ ចំពោះឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច គណៈបញ្ជាការឯកភាពបានចាត់ទុកជាឃុំមួយមានភាពស្មុគ្រស្មាញអំពីស្ថិតិប្រជាពលរដ្ឋ និងការប្រើប្រាស់អាវុធ ។ ប្រជាពលរដ្ឋភាគច្រើន ដែលបានមករស់នៅតំបន់នេះ ជាអ្នកចំណូលថ្មីមកពីបណ្តាខេត្តនានាតាំងទីលំនៅថ្មី ដើម្បីរកស៊ីចិញ្ចឹមជីវិតតាមមុខរបរចំរុះ ។ ភាគច្រើនប្រកបរបររុករកអនុផលព្រៃឈើ រុករានទន្ទ្រានធ្វើចំការ បរបាញ់សត្វព្រៃ ចាប់ដីសាងសង់ទីលំនៅ សង់រោងចាំដី ឬខ្ទមទុកចោលរាយប៉ាយ ដែលបង្កការលំបាកដល់អាជ្ញាធរ និងសមត្ថកិច្ចក្នុងការគ្រប់គ្រង ។ មិនតែប៉ុណ្ណោះតំបន់ទាំងនេះតែងតែកើតមានទំនាស់មិនចេះឈប់ឈរអំពីបាតុភាពដីធ្លី និងការបាញ់បោះ ។

លោក អៀង អុល ស្នងការរងប៉ូលីសខេត្តកំពង់ស្ពឺបានឱ្យដឹងថា កន្លងមកខេត្តបានបង្កើតគណៈកម្មការគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋ និងដកហូតអាវុធជាតិផ្ទុះមួយ ដោយមានកំលាំងចំរុះបានចូលរួមគ្រប់សមាសភាព ដើម្បីចុះស្រង់ស្ថិតិប្រជាពលរដ្ឋ និងដកហូតអាវុធគ្រប់ប្រភេទនៅក្នុងតំបន់ចំការចេក ឃុំត្រែងត្រយឹង ។ ក្នុងយុទ្ធនាការកាលនោះមានបែងចែកជា ៦ក្រុម ដើម្បីធ្វើការអនុវត្តន៍ ។ ជំហានទី១ធ្វើការអប់រំ និងផ្សព្វផ្សាយគោលការណ៍របស់ថ្នាក់លើ ក៏ដូចជាបណ្តាលិខិតបទដ្ឋាននានារបស់រាជរដ្ឋាភិបាល ស្តីពីការងារចុះស្ថិតិប្រជាពលរដ្ឋ និងការប្រើបាស់គ្រប់គ្រងអាវុធជាតិផ្ទុះ ។ បន្ទាប់មកទើបចាប់ដំណើរការអនុវត្តន៍ការចុះបញ្ជីស្នាម ។ ការអនុវត្តន៍លើកដំបូងឃើញប្រជាពលរដ្ឋចូលរួមបានល្អ ។ ថ្ងៃបន្តបន្ទាប់មានការស្មុគ្រស្មាញច្រើន ដោយប្រជាពលរដ្ឋមួយចំនួនពុំបានចូលរួម ។ ដូចនេះក្នុងរយៈពេលកន្លងមក ក្រុមការងារបានរកឃើញផ្ទះ រោង និងខ្ទមនៅក្នុងភូមិចំការចេកចំនួន ២៥០ខ្នង ។ ក្នុងចំនួននេះប្រជាពលរដ្ឋបានចូលរួមចុះបញ្ជីស្ថិតិគ្រួសារចំនួន ១៧៤គ្រួសារ នៅសល់ ៧៦គ្រួសារទៀត មិនព្រមសហការជាមួយសមត្ថកិច្ច ។ ដោយឡែក ការធ្វើបញ្ជី ឬតារាងផ្សាយរបាយការណ៍លើការគ្រប់គ្រងអាវុធវិញ ក្នុងចំណោម ២៥០ខ្នងផ្ទះនេះ ទើបសំរេចបានតែ ៦៧គ្រួសារ ប៉ុណ្ណោះ ។ ក្រៅពីនេះនៅអល់អែក និងមិនព្រមធ្វើតែម្តង ព្រោះខ្លាចការចុះបញ្ជីនេះយកទៅកាឡៃជារឿងផ្សេងៗទៅវិញ ។ បើតាមអ្នកស្រុកខ្លះនៅទីនោះបាននិយាយថា បើគ្រាន់តែចុះធ្វើបញ្ជីស្ថិតិពួកគាត់ចូលរួមបាន ។ ប៉ុន្តែបើឱ្យពួកគាត់បំពេញបែបបទនៅលើតារាងស្វ័យរាយការណ៍ពីបញ្ហាអាវុធ និងធ្វើការផ្តិតមេដៃលើឯកសារនោះ គាត់មិនចូលរួមទេ ព្រោះគាត់ខ្លាចយកមេដៃនេះទៅកាត់តបង្វែទៅជារឿងផ្សេងវិញ ។ ព្រោះថាកន្លងមកពួក

គាត់ធ្លាប់មានបាតុភាពដីធ្លីនៅកន្លែងនេះរាប់ដងទៅហើយ ។ ម្ល៉ោះហើយចង់ធ្វើអីមួយនៅទីនោះ ពួកគាត់ចេះតែរសើបជានិច្ច ។

ទោះបីជាជួបការលំបាកយ៉ាងណាក្តី សមត្ថកិច្ចខេត្តកំពង់ស្ពឺនៅតែបន្តខិតខំបំពេញការងារតាមនីតិវិធី និងខិតខំអប់រំឱ្យប្រជាពលរដ្ឋលោកបានយល់អំពីច្បាប់ទំលាប់នៃការផ្លាស់ប្តូរទីកន្លែង ការតាំងទីលំនៅដ្ឋានឱ្យបានស្របច្បាប់ និងគ្រប់គ្រងអាវុធជាតិផ្ទុះ មិនបណ្តោយឱ្យក្លាយទៅជាអនាធិបតេយ្យឡើយ ។/

## ប៉ៃលិន : រយៈពេល ៨ខែ មានមនុស្សស្លាប់ ១៦នាក់ និងរបួស ៦៣នាក់ ដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះ

*លោក ទិត ស្រី AKP ប៉ៃលិន*

លោក ឡឹម តូ មន្ត្រីកាកបាទក្រហមក្រុងប៉ៃលិន ផ្នែកប្រមូលទិន្នន័យជនរងគ្រោះដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះបានបញ្ជាក់ថា អត្រាគ្រោះថ្នាក់ដោយសារមីនរយៈ ៨ខែ ចាប់ពីខែមករា ដល់ខែសីហា មាន ៣៨ករណី មានជនរងគ្រោះរបួសចំនួន ៣៩នាក់ ស្លាប់ ០៦នាក់ រងគ្រោះថ្នាក់ពីគ្រាប់មិនទាន់ផ្ទុះមាន ១៦ករណី របួស ២៤នាក់ ស្លាប់ ១០នាក់ ជាមធ្យមគឺមានមនុស្សស្លាប់ ឬរបួស ៩ ទៅ ១០នាក់ក្នុងមួយខែ ។ លោក គក់ វុទ្ធី អនុប្រធានកងឯកភាពកម្ចាត់មីនទី៣ បានប្រាប់ឱ្យដឹងថា រយៈពេល ៣ខែ ចាប់ពីថ្ងៃទី១៥ ខែឧសភា ដល់ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៥ CMAC បានដោះមីនលើផ្ទៃដី ៧៦២៩៩៩ម$^{២}$ (៧៦ហិកតា) ដោះបានគ្រាប់មីនថ្មើជើងចំនួន ២៩៩៤គ្រាប់ មីនរថក្រោះបាន ៣០គ្រាប់ គ្រាប់មិនទាន់ផ្ទុះបាន ១៥០៣គ្រាប់ និងអំបែងគ្រាប់ ១.៦៨១.៣៦៣អំបែង ។

លោក កើត សុធា អភិបាលរងក្រុងប៉ៃលិន និងជាប្រធាន CMAC ក្រុងប៉ៃលិន បានមានប្រសាសន៍ក្នុងសិក្ខាសាលាស្តីពីការរៀបចំផែនការបោសសំអាតមីន និងគ្រាប់មិនទាន់ផ្ទុះប្រចាំឆ្នាំ២០០៦ របស់ CMAC នៅសាលាក្រុងប៉ៃលិន កាលពីថ្ងៃទី០៨ កញ្ញា ឆ្នាំ២០០៥នេះថា ក្រុមប្រឹក្សាឃុំ-សង្កាត់ កាន់តែពង្រឹងសមត្ថភាពរបស់ខ្លួនឱ្យបានល្អ ដើម្បីបញ្ចូលផែនការនៅក្នុងការកសាងផែនការបោសសំអាតមីន និងគ្រាប់មិនទាន់ផ្ទុះប្រចាំឆ្នាំ២០០៦ ។ លោកបានបន្តទៀតថា ត្រូវពិភាក្សាលើកគំរោងនិមួយៗឱ្យបានច្បាស់លាស់លើការដោះមីន និងគ្រាប់មិនទាន់ផ្ទុះ ត្រូវឯកភាពគ្នាតែមួយ ។ អភិបាលរងក្រុងប៉ៃលិនបញ្ជាក់ថា ការដោះមីនវាជាចម្បងក្នុងការកសាងសេដ្ឋកិច្ច និងសន្តិសុខសង្គម ជូនប្រជាពលរដ្ឋឈានទៅរកការអភិវឌ្ឍន៍លើវិស័យនានាជាច្រើនទៀត ។/

## រដ្ឋបាលព្រៃឈើឧត្ដុង្គ  បំផុសប្រជាពលរដ្ឋដាំដើមឈើឱ្យបានច្រើន

*លោក  លឹម  សាន AKP កំពង់ស្ពឺ*

ដើម្បីទប់ទល់សភាពការណ៍រាំងស្ងួត និងថែរក្សាបរិស្ថានធម្មជាតិ បច្ចុប្បន្នសង្កាត់រដ្ឋបាលព្រៃឈើឧត្ដុង្គ រួមជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នផ្សេងទៀត បានបំផុសប្រជាពលរដ្ឋឱ្យចូលរួមដាំកូនឈើជាចាំបាច់នៅតាមផ្ទះ តាមសាលារៀន វត្តអារាម និងទីកន្លែងដទៃទៀតដែលជាដីទំនេរ ជាមួយនឹងការបំផុសចលនាប្រជាពលរដ្ឋចូលរួមដាំកូនឈើថ្មីនេះ មន្ត្រីរដ្ឋបាលព្រៃឈើឧត្ដុង្គ រួមជាមួយអាជ្ញាធរមូលដ្ឋានក៏បានចែកកូនឈើហូបផ្លែដល់ប្រជាពលរដ្ឋចំនួន ៧១០ដើម ឱ្យពួកគាត់ទៅដាំតាមលំនៅដ្ឋានផងដែរ ។

លោក សេង លាង សង្កាត់រដ្ឋបាលព្រៃឈើឧត្ដុង្គបាននិយាយថា នៅក្នុងឆ្នាំ២០០៩នេះ យើងបានបំផុសស្មារតីប្រជាពលរដ្ឋនៅស្រុកឧត្ដុង្គទាំង ១៩ឃុំ ឱ្យចូលរួមដាំដើមឈើនៅតាមសងខាងផ្លូវលំក្រាលគ្រួសក្រហម តាមសាលារៀន និងតាមវត្តអារាមបានចំនួន ៣១៧៩ដើម ហើយក្នុងនោះ សង្កាត់រដ្ឋបាលព្រៃឈើឧត្ដុង្គផ្ទាល់ក៏បានដាំកូនឈើហូបផ្លែចំនួន ៧៧០ដើមផងដែរ ។ លោក សេង លាង បានបន្តថា បន្ទាប់ពីបានបំផុសឱ្យប្រជាជនចូលរួមដាំដើមឈើនៅតាមដងផ្លូវ សាលារៀន និងតាមវត្តអារាមរួចមក សង្កាត់រដ្ឋបាលព្រៃឈើឧត្ដុង្គ បានបំផុសស្មារតីប្រជាពលរដ្ឋឱ្យមានទឹកចិត្តចូលរួមដាំដើមឈើឱ្យបានច្រើនថែមទៀតនៅលើដីទំនេរតាមចន្លោះព្រៃរបោះ និងទីកន្លែងដែលមានព្រៃរិចរិល ។ ហើយបច្ចុប្បន្ននេះ យើងបានដាំកូនឈើចំនួន ២៤០៥ដើមថែមទៀត នៅតាមសងខាងផ្លូវលំក្រាលគ្រួសក្រហម តាមសាលារៀន និងតាមវត្តអារាម ក្នុងនោះមានកូនអាកាស្យាចំនួន ៥០០ដើម គ្មុម្ពទេស ៥០០ដើម ក្បៀក ២០០ដើម អង្កាញ់ ៥០ដើម ធ្នង់ ៤៥ដើម បេងចំនួន ១០០ដើម ហើយក៏បានចែកជូនកូនឈើហូបផ្លែដល់ប្រជាជននៅឃុំក្សេមក្សាន្តចំនួន ៧១០ដើមផងដែរ ក្នុងនោះមានដូងចំនួន ២១០ដើម ស្វាយ ២០០ដើម និងខ្នុរ ៣០០ដើម ឱ្យពួកគាត់ទៅដាំតាមលំនៅដ្ឋាន ។

នាយសង្កាត់រដ្ឋបាលព្រៃឈើបានគូសបញ្ជាក់ថា ការដាំដើមឈើឱ្យដុះលូតលាស់បានល្អ ទាមទារការថែទាំដាក់ជី បោចស្មៅ និងមិនឱ្យសត្វ ឬមនុស្សបំផ្លិចបំផ្លាញផងដែរ បើគ្រាន់តែដាំៗឱ្យរួចពីដៃ ពិតជាមិនទទួលបានលទ្ធផលល្អឡើយ ។/

## ចរាចរគ្រឿងញៀននៅក្រុងព្រះសីហនុមិនទាន់បង្រ្កាបបាន

*លោក  ង៉ូ  សុមុនី AKP ក្រុងព្រះសីហនុ*

លោក យិន ប៊ុនណាត ស្នងការរងក្រុងព្រះសីហនុ បានឱ្យដឹងថា សភាពការណ៍គ្រឿងញៀនក្នុងក្រុងព្រះសីហនុ ដែលពួកជនល្មើសនាំចូលមកចរាចរលក់ និងចែកចាយនៅតាមផ្ទះសំណាក់ ផ្ទះជួលហាងខារ៉ាអូខេ ឌីស្កូតេក ហើយអ្នកប្រើប្រាស់ទាំងនោះ សុទ្ធសឹងជាពួកយុវវ័យ មានដូចជាសិស្ស ក្រុមបងធំ និងពួកក្មេងអនាថា ។ល។

ដោយអនុវត្តតាមសេចក្តីណែនាំលេខ០០៩ របស់ក្រសួងមហាផ្ទៃ និងបទបញ្ជាលេខ០០២ របស់អគ្គស្នងការនគរបាលជាតិស្តីពីវិធានការទប់ស្កាត់ និងបង្ក្រាបការជួញដូរគ្រឿងញៀន នៅតាមបណ្តាខេត្ត-ក្រុងឱ្យមានប្រសិទ្ធភាព ។

លទ្ធផលក្នុងឆមាសទី១ ឆ្នាំ២០០៩នេះ កម្លាំងជំនាញរបស់ស្នងការនគរបាលក្រុងព្រះសីហនុ បានសហការជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ធ្វើការចុះបង្ក្រាបបទល្មើសគ្រឿងញៀនបានចំនួន០៣លើក ដោយឃាត់ខ្លួនជនសង្ស័យបានចំនួន ០៧នាក់ ក្នុងនោះមានស្ត្រី ០៤នាក់ ដកហូតវត្ថុតាងមានថ្នាំញៀនសំយោគប្រភេទថ្នាំមេតំហ្វេតាមីនពណ៌ឈាមជ្រូកចំនួន ២៥២គ្រាប់ និងថ្នាំញៀនសំយោគ ០១កញ្ចប់ ប្រមាណជា ២០០គ្រាប់ ព្រមទាំងឆែកឆេររកឃើញក្នុងបន្ទប់ទឹកមានថ្នាំញៀនសម្រាប់ជក់ ១០ សេរ៉ូម ព្រមទាំងនិងសំណាកសង្ស័យផ្សេងៗទៀត ។ កម្លាំងជំនាញធ្វើការបង្ក្រាប និងកាប់បំផ្លាញកញ្ឆាបានចំនួន ១.០៣១ គ.ក្រ ផងដែរ ។

លោកស្នងការរងក្រុងព្រះសីហនុបានបញ្ជាក់ទៀតថា កម្លាំងជំនាញក៏បានប្រមូលជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនយកមកធ្វើការអប់រំណែនាំបាន ០៤លើក មានអ្នកប្រើប្រាស់ថ្នាំញៀនចំនួន ១១នាក់ ដោយធ្វើការអប់រំណែនាំអំពីផលប៉ះពាល់ដោយសារគ្រឿងញៀន ឱ្យពួកគេសំរេចចិត្តលះបង់គ្រឿងញៀនឱ្យបានជាដាច់ខាត បើមិនដូច្នោះទេ ផលអាក្រក់គ្រប់បែបយ៉ាងនឹងធ្លាក់មកលើខ្លួនមិនអាចរស់នៅក្នុងសង្គមជាតិ ឬក្រុមគ្រួសារបានទេ ។ អ្នកសេពគ្រឿងញៀន បានយល់ព្រមធ្វើកិច្ចសន្យាយល់ព្រមឈប់សេពគ្រឿងញៀនដោយឱ្យអាណាព្យាបាលមកធានាយកទៅផ្ទះវិញ ។ ស្នងការដ្ឋាននគរបាលក្រុងព្រះសីហនុបានទទួលស្គាល់ថា: យើងក៏មិនទាន់ប្រមូលអ្នកញៀនថ្នាំ មកធ្វើការអប់រំកែប្រែឱ្យបានដល់ក៏រិតព្រោះយើងខ្វះកន្លែងអប់រំកែប្រែដូចនៅខេត្តបន្ទាយមានជ័យ ។ មន្ត្រីស្នងការប៉ូលិសអះអាងថា បើយើងមានមជ្ឈមណ្ឌលអប់រំកែប្រែ និងចាត់វិធានការក្តៅតាមច្បាប់ប្រាកដប្រជា ធ្វើឱ្យអ្នកជក់គ្រឿងញៀនមានការថយចុះ ។

ទិន្នន័យពីការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការនគរបាលក្រុងព្រះសីហនុ ប្រមូលបានគិតមកដល់ខែឧសភា ឆ្នាំ២០០៥នេះ មានចំនួនអ្នកប្រើប្រាស់គ្រឿងញៀន ៦០៤នាក់ ក្នុងនោះអ្នកប្រើប្រាស់មានចំនួន ៥៩៤នាក់ និងអ្នកចែកចាយចំនួន ១០នាក់ ហើយជនទាំងអស់នោះ មានអាយុពី ២៥ឆ្នាំ ទៅ ៤៥ឆ្នាំ ។/

## សកម្មភាពការងាររយៈពេល ៤ឆ្នាំ របស់សាខាកាកបាទក្រហមខេត្តកំពង់ធំ

*លោក ស៊ុម វណ្ណា AKP កំពង់ធំ*

ក្នុងរយៈពេល ៤ឆ្នាំ គិតពីខែមិថុនា ២០០១ ដល់ ខែមិថុនា ២០០៥ គណៈកម្មាធិការសាខាកាកបាទក្រហមខេត្តកំពង់ធំបានអនុវត្តយ៉ាងសកម្មស្វះស្វែងរកជំនួយថវិកា ដើម្បីជួយទ្រទ្រង់សកម្មភាពសាខាកាកបាទក្រហមខេត្តកំពង់ធំក្នុងការជួយសំរាលទុក្ខលំបាកវេទនា និងការខ្វះខាតស្បៀង ផ្នែកជីវភាពរស់នៅរបស់ជនរងគ្រោះធ្ងន់ធ្ងរជាងគេ ។

លោក លី គីមសាង នាយកប្រតិបត្តិសាខាកាកបាទក្រហមខេត្តកំពង់ធំបញ្ជាក់ថា ក្នុងរយៈពេល ៤ឆ្នាំនេះ សាខាកាកបាទក្រហមខេត្តបានធ្វើការបែងចែកផ្តល់ជំនួយដល់ជនរងគ្រោះដោយប្រការផ្សេងៗបានទាន់ពេលវេលាបានចំនួន ១៨.២៦១គ្រួសារ ក្នុងនោះរងគ្រោះដោយភ្លើងឆេះផ្ទះចំនួន ៥២៤គ្រួសារ ខ្យល់ព្យុះរលំផ្ទះ ៩៥៣គ្រួសារ ខ្យល់ព្យុះរបើកដំបូល ២២៤គ្រួសារ គ្រោះទឹកជំនន់ ១.៥៣០គ្រួសារ ប្រជាជនក្រីក្រដាច់ស្បៀង ២.២១៣គ្រួសារ ប្រជាជនជួបគ្រោះរាំងស្ងួតចំនួន ១២.៥៨០គ្រួសារ កូនភ្លោះ៤គ្រួសារ រន្ទះបាញ់ស្លាប់ និងរបួស ៨នាក់ អ្នកកើតជម្ងឺអេដស៍ និងអ្នកផ្ទុកមេរោគអេដស៍ ១៩នាក់ កុមារកំព្រា ៥នាក់ និងចាស់ជរា ៣នាក់ ។

ក្នុងរយៈពេល ៤ឆ្នាំនេះ សាខាកាកបាទក្រហមកម្ពុជាខេត្តកំពង់ធំបានផ្តល់នូវអំណោយ ដែលបានទទួលពីកាកបាទក្រហមកម្ពុជានូវអង្ករចំនួន ៣១៣តោន មុង ៦.៧៥២ សារុង ១២.៥៧៨ ក្រមា ១២.២៦២ ខោអាវ ១២.២៦២ ក្រណាត់កៅស៊ូ ២.៤០០ ធុងទឹក ១.៨០៤ ថង់ប្លាស្ទិក ១៧.៩៩០ សប៊ូដុំ ៧.៥៨០ដុំ សាប៊ូម្សៅ ១.០៧២គ.ក្រ និង ៦កាតុង ថ្នាំពេទ្យ ៣៦កាតុង នំបីស្គី ៣៧កាតុង មី ១០.២០៩កញ្ចប់ ត្រីខ ៦.១២២កំប៉ុង រទេះជនពិកា ១៨រទេះ និងកង់ ២៥គ្រឿង ។ អំណោយរបស់អង្គការ I.F.R.T ចំនួន ២០មុខ ៨៦០ឃីត ។ អំណោយរបស់កាកបាទក្រហមប៊ែលហ្សិក ៩មុខ ៧៥០ឃីត ។ អំណោយរបស់អង្គការគ្រឹះសាសនាបំរើពិភពលោកប្រចាំខេត្តកំពង់ធំ ១១មុខ មាន ៣០០ឃីត។ សាខាកាកបាទក្រហមខេត្តកំពង់ធំទិញសម្ភារៈសំរាប់ចែកជូនប្រជាជនរងគ្រោះដោយសារភ្លើងឆេះផ្ទះ ខ្យល់ព្យុះ រលំផ្ទះ ៧មុខ ៤៥៣ឃីត ទិញសម្ភារៈចែកជូនដល់ប្រជាជនក្រីក្រខ្វះខាតស្បៀង ៤មុខ ៧៧៨ឃីត មន្ទីរសង្គមកិច្ចខេត្តកំពង់ធំជួយឧបត្ថម្ភមុងចំនួន ៤០មុង តង់ខៀវចំនួន ៧៥៤ កន្ទេល ៧៥៤ ។ ក្រុមហ៊ុនយូធីលីធីជួយឧបត្ថម្ភអង្ករចំនួន ៤២តោន និងសប្បុរសជនក្នុង និងក្រៅប្រទេសជួយឧបត្ថម្ភនូវអង្ករជាង ១០៧តោន ក្រមា ៦៩០ សរុង ១៩០ កង់ ១៧គ្រឿង និងថ្នាំពេទ្យ ២.១០០គ្រាប់ និង ៥៣០កញ្ចប់ ។

លោក លី គឹមសាង បញ្ជាក់ថា : ដោយមានលោកជំទាវ ប៊ុន រ៉ានី ហ៊ុន សែន ជាប្រធានកាកបាទក្រហមកម្ពុជា បានជះឥទ្ធិពលគ្របដណ្តប់ទូទាំងប្រទេស ធ្វើឱ្យសាខាកាកបាទក្រហមខេត្តកំពង់ធំទទួលបាននូវការគាំទ្រពីអាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងមានការរីកចំរើនជាលំដាប់ ។

ផែនការជាយុទ្ធសាស្ត្រ ២០០៣-២០១០ បានបង្ហាញឱ្យឃើញនូវទស្សនៈសំខាន់ៗជាគន្លឹះ ។ សាខាកាកបាទក្រហមខេត្តកំពង់ធំអាចដំណើរការបានល្អ អាស្រ័យដោយសារមានគណៈកម្មាធិការ ដែលសកម្ម មានគំនិតផ្តួចផ្តើមច្រើន មានគោលការណ៍អភិបាលកិច្ចល្អ ហើយក្រុមប្រតិបត្តិមានឆន្ទៈទទួលខុសត្រូវខ្ពស់ ប្រឹងប្រែងព្យាយាម មានការវាងវៃ ចេះកែច្នៃស្ថានភាពជាក់ស្តែង ធ្វើយ៉ាងណា គៀងគររកមូលនិធិដើម្បីជួយសង្គ្រោះដល់ជនរងគ្រោះនៅតាមសហគមន៍ ជួយលើកកំពស់កិត្តិយសរបស់សមាគមជាតិ ធ្វើការអភិវឌ្ឍន៍ស្ថាប័នរបស់ខ្លួនចាប់ពីថ្នាក់កណ្តាលរហូតដល់សហគមន៍ ថែរក្សាបំប៉នពង្រឹងពង្រីកអ្នកស្ម័គ្រចិត្ត និងយុវជនកាកបាទក្រហមខេត្ត ។

លទ្ធផលរបស់សាខាកាកបាទក្រហមខេត្តកំពង់ធំអនុវត្តបានក្នុងរយៈពេល ៨ឆ្នាំនេះ បានឆ្លុះបញ្ចាំងឱ្យឃើញនូវស្មារតីជាប្រពៃណីរបស់ប្រជាជនកម្ពុជាយើង គឺរួមកម្លាំងគ្នាដើម្បីមនុស្សធម៌” ។/